២៧. ទណ្ឌិតឈ្មោះ **ព្រឹម ស្រេង** ភេទប្រុស អាយុ ២៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៥-១០-៩៤ ពីបទមនុស្សឃាដគិតទុកជាមុន ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ ឆ្នាំ តាមអំណាចសាលក្រមលេខ ១១ ចុះថ្ងៃទី ០៧-៣-៩៥ របស់តុលាការខេត្តព្រៃវែង ។

២៨. ទណ្ឌិតឈ្មោះ **ស ឈឹម** ភេទប្រុស អាយុ ៤០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៥-៦-៨៩ ពីបទធ្វើមនុស្សឃាដដោយចេតនា មានអាវុធ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ឆ្នាំ តាមអំណាចសាលក្រមលេខ ២៣ ចុះថ្ងៃទី ១៧-៩-៩២ របស់តុលាការខេត្តកំពង់ធំ ។

២៩. ទណ្ឌិតឈ្មោះ **ឡាត់ ឌុយ** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២២-៧-៨៩ ពីបទប្លន់ទ្រព្យសម្បត្តិប្រជាជនច្រើនលើក មានអាវុធរួចសម្លាប់ដោយចេតនា ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ឆ្នាំ តាមអំណាចសាលក្រមលេខ ១២ ចុះថ្ងៃទី ០៩-៧-៩២ របស់តុលាការខេត្តកំពង់ធំ ។

៣០. ទណ្ឌិតឈ្មោះ **ពេជ សួន** ភេទប្រុស អាយុ ៣១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៤-១១-៩៤ ពីបទឃាដកម្មគិតទុកជាមុន ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ២១ ចុះថ្ងៃទី ២០-៤-៩៥ របស់តុលាការខេត្តកំពង់ធំ ។

៣១. ទណ្ឌិតឈ្មោះ **ហេង នាត** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៨-៤-៩១ ពីបទធ្វើមនុស្សឃាដដោយចេតនា មានអាវុធ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៤ឆ្នាំ តាមអំណាចសាលក្រមលេខ ២០ ចុះថ្ងៃទី ២១-៨-៩២ របស់តុលាការខេត្តកំពង់ធំ ។

៣២. ទណ្ឌិតឈ្មោះ **នាយ សុផាន** ហៅ ត ភេទប្រុស អាយុ ២៧ ឆ្នាំ ត្រូវចាប់ខ្លួននៅ

ថ្ងៃទី០២-៩-៨៥ ពីបទចាប់បង្ខំស្ត្រីភេទសេពសន្ថវៈ រួចសម្លាប់ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត តាមអំណាចសាលក្រមលេខ ០១ ចុះថ្ងៃទី ២៦-០២-៨៦ របស់តុលាការក្រុងព្រះសីហនុ ។

មាត្រា ៥ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ

មាត្រា ៦ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

នស/រកត.០៣.១២.៣៥៤

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៣

លេខ: ០៣ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាឌី តាន់

ព្រះរាជក្រឹត្យ

នស/រកត/០១០៤/០០១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០៣/២១១ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីការធ្វើសមាហរណកម្ម ទៅក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។

ត្រាស់បង្គាប់

មាត្រា ១ .–

ត្រូវបានតម្លើងឋានន្តរស័ក្តិជូន ឯកឧត្តម ខិន យ៉េង ពីវរមន្ត្រីថ្នាក់លេខ ៤ ទៅឧត្តមមន្ត្រីថ្នាក់លេខ ៥ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ។

មាត្រា ២ .–

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ .–

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ .–

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

នស/រកត.០៤.០១.០០១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០៤

លេខ: ០៥ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ២០០៤

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សុខ អាន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ..០១...អនក្រ..គក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួង ការពារជាតិ

ស ម្រេ ច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនលោកវរសេនីយ៍ឯក *SEA NGEANLIM* តំណាងនាយកដ្ឋាន បច្ចេកទេសវិស្វកម្ម ក្រសួងការពារជាតិ នៃ សាធារណរដ្ឋប្រជាមានិតចិន ដែលមាន ស្នាដៃល្អក្នុងការសហការជួយឧបត្ថម្ភ ដល់កងយោធពលខេមរភូមិន្ទ នៅព្រះរាជាណាចក្រកម្ពុជា រយៈពេល ០៣ឆ្នាំ កន្លងមក ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u> :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០២ . អនក្រ . តត

អនុក្រឹត្យ
ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សំរេច

មាត្រា១ : ផ្តល់គ្រឿងឥស្សរិយយស មេដាយស្ថាបនាជាតិ ជូនសប្បុរសជន និងក្រុមហ៊ុន ដែលបានបរិច្ចាគថវិកាជួយឧបត្ថម្ភដល់ការកសាងវិមានសពេ យោធភូមិភាគទី៤ ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយប្រាក់ស្ថាបនាជាតិ :

-ក្រុមហ៊ុន ស៊ីង អេខឡុង ទឹកប្រាក់ចំនួន ៥.០០០ ដុល្លារអាមេរិក

ខ-មេដាយសំរឹទ្ធស្ថាបនាជាតិ :

១-ឯកឧត្តម	ចម	ប្រសិទ្ធ	រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម	ទឹកប្រាក់ចំនួន ១.៤០០	ដុល្លារអាមេរិក
២-ឧកញ៉ា	សៀង	ណាំ	តំណាងរាស្ត្រមណ្ឌលសៀមរាប	ទឹកប្រាក់ចំនួន ២.០០០	ដុល្លារអាមេរិក
៣-ឧកញ៉ា	ចាន់	ហៀត	អគ្គនាយកដ្ឋាន ចំការកៅស៊ូ	ទឹកប្រាក់ចំនួន ២.០០០	ដុល្លារអាមេរិក
៤-ឯកឧត្តម	ទោស្មិ	សាវឿន	អគ្គនាយកក្រសួងទេសចរណ៍	ទឹកប្រាក់ចំនួន ១.០០០	ដុល្លារអាមេរិក
៥-អនុសេនីយ៍ឯក	ឡឹម	នារី	នាយទាហានយោធភូមិភាគទី៤	ទឹកប្រាក់ចំនួន ១.០០០	ដុល្លារអាមេរិក
៦-លោក	អ៊ឹ	ឃឿន	មេជាងសំណង់	ទឹកប្រាក់ចំនួន ១.០០០	ដុល្លារអាមេរិក

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ និងអគ្គមេបញ្ជាការ កងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០

ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៦៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

&&&&&

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សំរេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយការងារ** ជូនដល់នាយទាហាន ចំនួន ៩៤រូប ចំណុះយោធភូមិភាគទី៤ បញ្ជាការដ្ឋាន កងទ័ពជើងគោក អគ្គបញ្ជាការដ្ឋាន ដូចមានរាយនាមខាងក្រោម ÷

ក-មេដាយមាសការងារ ចំនួន ២២ គ្រឿង :

១-ឧត្តមសេនីយ៍ទោ	ជា	មិន	អត្តលេខ ០០០១៣៥	មេបញ្ជាការ	យោធភូមិភាគទី ៤
២-ឧត្តមសេនីយ៍ទោ	ទិត្យ	សុខនាព	អត្តលេខ ០០០១៤០	មេបញ្ជាការ	កងពលធំអន្តរាគមន៍លេខ២
៣-ឧត្តមសេនីយ៍ត្រី	ព្រហ្ម	សាវេន	អត្តលេខ ០០០១៣៤	មេបញ្ជាការរង	យោធភូមិភាគទី ៤
៤-ឧត្តមសេនីយ៍ត្រី	ស	សារឿន	អត្តលេខ ០០០១៦០	មេបញ្ជាការរង	យោធភូមិភាគទី ៤
៥-ឧត្តមសេនីយ៍ត្រី	យឹម	ផាន់ណា	អត្តលេខ ០០៤៣៥០	មេបញ្ជាការរង	យោធភូមិភាគទី ៤
៦-ឧត្តមសេនីយ៍ត្រី	ទឹម	គេម	អត្តលេខ ០០៤៣៥៦	មេបញ្ជាការរង	យោធភូមិភាគទី ៤
៧-ឧត្តមសេនីយ៍ត្រី	ជា	កែវ	អត្តលេខ ០០៤៣៥១	មេបញ្ជាការរង	យោធភូមិភាគទី ៤
៨-ឧត្តមសេនីយ៍ត្រី	កែវ	ធី	អត្តលេខ ០០០១៣៧	មេបញ្ជាការរង	និងជានាយសេនាធិការ
៩-ឧត្តមសេនីយ៍ត្រី	ប៉ឺន	ម៉ូយ	អត្តលេខ ០០៣៨១២	មេបញ្ជាការ	កងពលតូចលេខ ៤

១០-ឧត្តមសេនីយ៍ត្រី	ម៉ើម	ពិម	អត្តលេខ ០០៤៣៥០	មេបញ្ជាការ កងពលតូចលេខ ៤៣
១១-ឯកឧត្តម	ទ្ធិង	អឿន	អត្តលេខ ០០០៣៧២	អភិបាលរងទី ១ ខេត្តសៀមរាប
១២-វរសេនីយ៍ឯក	ពៅ	ហេង	អត្តលេខ ០០០៩៦១	នាយរងសេនាធិការ យោធភូមិភាគទី ៤
១៣-វរសេនីយ៍ឯក	នួន	នៅ	អត្តលេខ ០០៤៨២៨	នាយរងសេនាធិការ យោធភូមិភាគទី ៤
១៤-វរសេនីយ៍ឯក	សោ	ណារុង	អត្តលេខ ០០០៧៧៦	មេបញ្ជាការ កងពលតូចលេខ ៤១
១៥-វរសេនីយ៍ឯក	នួយ	ម៉ុនរ៉េត	អត្តលេខ ០០១១៧០	មេបញ្ជាការរង និងជានាយសេនាធិការ កងពលតូចលេខ ៤១
១៦-វរសេនីយ៍ឯក	ឃឹម	ម៉ុនសួង	អត្តលេខ ០០០៩៧០	មេបញ្ជាតំបន់ប្រតិបត្តិការសឹករងសៀមរាប
១៧-វរសេនីយ៍ឯក	ហាឡៃ	ថុល	អត្តលេខ ០០០៥២០	មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងកំពង់ធំ
១៨-វរសេនីយ៍ឯក	ម៉ុត	សុផណ្ណ	អត្តលេខ ០០០៣៨៧	មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងឧត្តរមានជ័យ
១៩-វរសេនីយ៍ឯក	យ៉ាត	ផល្លាសុទ្ធ	អត្តលេខ ០០០៣៨៩	មេបញ្ជាការ តំបន់ប្រតិបត្តិការសឹករងព្រះវិហារ
២០-វរសេនីយ៍ឯក	ឈុំ	ខេង	អត្តលេខ ០០១០០៥	មេបញ្ជាការ កងពលតូចលេខ៤កងពលធំលេខ២
២១-វរសេនីយ៍ឯក	សិរិទ្ធ	សារ៉េត	អត្តលេខ ០០១០០៦	មេបញ្ជាការ កងពលតូចលេខ៥កងពលធំលេខ២
២២-វរសេនីយ៍ទោ	ព្រហ្ម	សំអូល	អត្តលេខ ០០០៩៦៥	នាយការិយាល័យទី ៥ យោធភូមិភាគទី ៤

ខ-មេដាយប្រាក់ការងារ ចំនួន ២១ គ្រឿង :

១-វរសេនីយ៍ឯក	ម៉ៀម	សុខេង	អត្តលេខ ០០០៣២៣	នាយរងសេនាធិការ	យោធភូមិភាគទី ៤
២-វរសេនីយ៍ទោ	ព្រាប	សារុណ	អត្តលេខ ០០០៩៦០	នាយការិយាល័យទី១	យោធភូមិភាគទី ៤
៣-វរសេនីយ៍ទោ	ឆង់	ឆា	អត្តលេខ ០០២៨៨៤	នាយការិយាល័យទី២	យោធភូមិភាគទី ៤
៤-វរសេនីយ៍ទោ	នាង	ឃឹម	អត្តលេខ ០០១១៥៩	នាយការិយាល័យទី៣	យោធភូមិភាគទី ៤
៥-វរសេនីយ៍ទោ	ស៊ុន	គីមថៃ	អត្តលេខ ០០០៩៦៣	នាយការិយាល័យទី៤	យោធភូមិភាគទី ៤
៦-វរសេនីយ៍ទោ	យឹង	សារុន	អត្តលេខ ០០២៨៨៣	នាយការិយាល័យ ហិរញ្ញ	យោធភូមិភាគទី៤
៧-វរសេនីយ៍ទោ	ភួយ	នឹម	អត្តលេខ ០០២៨៥៨	នាយការិយាល័យយោធាតំបន់	យោធភូមិភាគទី៤
៨-វរសេនីយ៍ទោ	ទឹម	ឆឿង	អត្តលេខ ០០៩៩៥៨	នាយលេខាធិការដ្ឋាន	យោធភូមិភាគទី៤
៩-វរសេនីយ៍ទោ	ឡុង	សារ៉េត	អត្តលេខ ០០២៨៦៦	នាយការិយាល័យអភិវឌ្ឍន៍	យោធភូមិភាគទី៤
១០-វរសេនីយ៍ទោ	សួរ្យ	ណារ៉ា	អត្តលេខ ០០២១៣១	នាយផ្នែកការពារព្រំដែន	យោធភូមិភាគទី៤
១១-វរសេនីយ៍ទោ	ស្វង	សាម៉ុន	អត្តលេខ ០០០៩៦៧	នាយតំបន់អភិវឌ្ឍន៍	យោធភូមិភាគទី៤
១២-វរសេនីយ៍ទោ	រស់	សារិន	អត្តលេខ ០០២៨៧១	នាយផ្នែកហិរញ្ញវត្ថុ	យោធភូមិភាគទី៤
១៣-វរសេនីយ៍ទោ	សោម	អៀងលី	អត្តលេខ ០០០៩៨៧	មេបញ្ជាការកងការពារព្រំដែន ៤០១	
១៤-វរសេនីយ៍ទោ	ទីន	ចាន់	អត្តលេខ ០០០៩៨៣	មេបញ្ជាការកងការពារព្រំដែន ៤០២	
១៥-វរសេនីយ៍ទោ	ឆឿង	ឆា	អត្តលេខ ០០៩៩៨៦	មេបញ្ជាការកងការពារព្រំដែន ៤០៣	

១៦-វរសេនីយ៍ត្រី ឈន ឆឺ អត្តលេខ ០០៩៩៥៩ នាយរងផ្នែកហិរញ្ញវត្ថុ យោធភូមិភាគទី ៤

១៧-វរសេនីយ៍ត្រី ចេស សាខេន អត្តលេខ ០០៨២៤៤ នាយរងការិយាល័យទី១ យោធភូមិភាគទី ៤

១៨-អនុសេនីយ៍ឯក ទៀម ម៉ុណ្ណា អត្តលេខ ០១៩០៤៨ នាយឯកទេសវិស្វកម្ម យោធភូមិភាគទី ៤

១៩-អនុសេនីយ៍ឯក អ៊ុច នីរត្ន អត្តលេខ ០០៩៩៧២ ជំនួយការគោលនយោបាយការិយាល័យទី៥យោធភូមិភាគទី

២០-អនុសេនីយ៍ឯក សឿន ស្រីមុំ អត្តលេខ ០១៨៩៩៥ ជំនួយការពត៌មានការិយាល័យទី២យោធភូមិភាគទី៤

២១-អនុសេនីយ៍ឯក ម៉ែន សារឿន អត្តលេខ ០១៨៩៧២ ជំនួយការស្មៀនលេខាធិការដ្ឋានយោធភូមិភាគទី៤

គ-មេដាយសិរីវឌ្ឍការងារ ចំនួន ១១ គ្រឿង :

១-វរសេនីយ៍ឯក ហ៊ីម សារ៉ន អត្តលេខ ០០០៤៥៦ នាយរងសេនាធិការ យោធភូមិភាគទី ៤

២-វរសេនីយ៍ឯក ផូ គ្រួយ អត្តលេខ ០០៤៤១១ នាយរងសេនាធិការ យោធភូមិភាគទី ៤

៣-វរសេនីយ៍ទោ ខ្លូច សុខរិទ្ធ អត្តលេខ ០០២៨៨០ នាយកមន្ទីរពេទ្យ យោធភូមិភាគទី ៤

៤-វរសេនីយ៍ទោ ពែត សាម៉ាន អត្តលេខ ០០២១៧៧ នាយកសាលាពលទាហាន យោធភូមិភាគទី ៤

៥-វរសេនីយ៍ត្រី គីម ហាប់ អត្តលេខ ០០២៨៥២ នាយរងការិការិយាល័យទី៤ យោធភូមិភាគទី ៤

៦-វរសេនីយ៍ត្រី ចិន្តា មុន្នីសោត្រី អត្តលេខ ០០២៨៥០ នាយរងការិយាល័យទី៣ យោធភូមិភាគទី ៤

៧-អនុសេនីយ៍ឯក ម៉ី សឿម អត្តលេខ ០២៩៥០៨ មេបញ្ជាការវរសេនាតូចស៊ើបការណ៍យោធភូមិភាគទី៤

៨-អនុសេនីយ៍ឯក ម៉ុច តារា អត្តលេខ ០១២៩៩២ មេបញ្ជាការវរសេនាតូចវិស្វកម្មយោធភូមិភាគទី៤

៩-អនុសេនីយ៍ឯក ហ៊ឹម ចែម អត្តលេខ ០១៨៩៧០ នាយឯកទេសបញ្ជូនសារ យោធភូមិភាគទី៤

១០-អនុសេនីយ៍ឯក ពៅ វុន អត្តលេខ ០១៩០១៥ នាយរងការិយាល័យទី៥ យោធភូមិភាគទី៤

១១-អនុសេនីយ៍ឯក ពរ គឹមហ៊ិប អត្តលេខ ០១៩០៦៤ នាយរងលេខាធិការដ្ឋាន យោធភូមិភាគទី៤

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ និងអគ្គមេបញ្ជាការ កងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០៤

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ពានជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា

សម្រេច

មាត្រា១ៈ ត្រូវបានបំពាក់ **មេដាយមាសស្ពានជាតិ** ចំនួន ០២ គ្រឿង ជូនសប្បុរសជន ចំនួន ០២ រូប តំណាងអង្គការ *ENFANTS D'ASIE ASPECA* ដែលបានផ្តល់ថវិកា សំរាប់ជួយសាងសង់អគារសិក្សាពតិមានវិទ្យា ចំនួន០១ខ្នង ផ្ទះបាយ០១ខ្នង និង បំពាក់សម្ភារៈផ្សេងៗ ជូនមណ្ឌលកុមារកំព្រា ខេត្តតាកែវ ចំណាយអស់ ទឹកប្រាក់ ចំនួន ៧៩.៥៥២ ដុល្លារ ដូចមានរាយនាមខាងក្រោម :-

១-លោក ***Ettienne Roussel*** ប្រធានអង្គការ *ENFANTS D'ASIE ASPECA* នៅទីក្រុង *Paris.*

២-លោកស្រី **គិម គីមឡាង** នាយកអង្គការ *ENFANTS D'ASIE ASPECA*

មាត្រា២ ៈ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និង អភិបាលខេត្តតាកែវ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០០៤

ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច ✓
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៥ អនក្រ-តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា

ស ម្រេ ច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០២គ្រឿង ជូនសប្បុរសជន ចំនួន០២រូប តំណាងអង្គការ មូលនិធិ កម្ពុជា-អាមេរិក ដែលបានផ្តល់ថវិកា សំរាប់ជួយដល់ប្រជាពលរដ្ឋក្រីក្រកម្ពុជា នៅតាមព្រំដែន ភាគខាងលិច ដូចជាជួយសាងសង់លំនៅដ្ឋាន ឧបត្ថម្ភស្បៀងអាហារ ។ល។ ចំណាយអស់ទឹកប្រាក់ ចំនួន ២១.៦៣៤.៣៨ ដុល្លារ ដូចមានរាយនាមខាងក្រោម :-

១-លោក **តុំ ម៉ាន់តារា** ប្រធានអង្គការ មូលនីធិកម្ពុជា-អាមេរិក ដើម្បីជួយជនក្រីក្រ ប្រចាំសហរដ្ឋ អាមេរិក

២-លោកស្រី **ឆាន ស្រីមុំ** ប្រធានអង្គការ មូលនីធិកម្ពុជា-អាមេរិក ដើម្បីជួយជនក្រីក្រ ប្រចាំកម្ពុជា

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៤

ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច ✓
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៦ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សំរេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ជូនតំណាងនាយកដ្ឋានបច្ចេកទេសវិស្វកម្ម ក្រសួងការពារជាតិ នៃសាធារណរដ្ឋប្រជាមានិតចិន ចំនួន ០២ រូបដូចមានរាយនាមខាងក្រោម ÷

ក_មេដាយសហមេត្រី ថ្នាក់សេនា :

_ឯកឧត្តម ឧត្តមសេនីយ៍ទោ យូ ឌុនកាយ Major General YU DUN CAI

ខ_មេដាយសហមេត្រី ថ្នាក់អស្សឫទ្ធិ :

_លោក កៅ វ៉េស៊ិន Mr. CAO WEI XIN

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ និងអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ,ថ្ងៃទី [illegible] ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៦៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលស្រុក ល្វាឯម ខេត្តកណ្តាល

សំរេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០៣រូប ដែលបានបរិច្ចាគធនធាន ផ្ទាល់ខ្លួន ជួយកសាងសមិទ្ធផលផ្សេងៗ ក្នុងស្រុកល្វាឯម ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម :-

១-ឯកឧត្តម	**ហាវ ម៉ុនសែ**	ទីប្រឹក្សា សម្តេចនាយករដ្ឋមន្ត្រី		ថវិកា ចំនួន ១២.៣០០ USD
២-ឯកឧត្តម	**ម៉ុក ធារី**	ជំនួយការសម្តេចនាយករដ្ឋមន្ត្រី		ថវិកា ចំនួន ១១.២០០ USD
៣-លោក	**ស៊ំ លន់**	ប្រធានមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខេត្តកណ្តាល		ថវិកា ចំនួន ១០.៧៥០ USD

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវ អនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ ថ្ងៃ [illegible] ខែ [illegible] ឆ្នាំ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...០៥...អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ នាយកមន្ទីរពេទ្យព្រះកេតុមាលា

ស ម្រេ ច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនក្រុមគ្រូពេទ្យស្ម័គ្រចិត្ត នៃ មន្ទីរពេទ្យព្រះកេតុមាលា ចំនួន ៤៨រូប ដែលមានស្នាដៃល្អ ក្នុងការចុះព្យាបាលជំងឺជូនប្រជាពលរដ្ឋ តាមជនបទ និងតាមការដ្ឋាននានា នៃក្រុមវិស្វកម្ម ដូចមានរាយនាមខាងក្រោម :-

ក-មេដាយមាសការងារ :

១-លោកស្រី	**គួប**	**សារិន**
២-លោកវេជ្ជបណ្ឌិត	**វ័ន្ត**	**ផារ៉ា**
៣-លោកវេជ្ជបណ្ឌិត	**គួយ**	**រ៉ា**
៤-លោកវេជ្ជបណ្ឌិត	**ភាន**	**ឈឹមសួន**
៥-លោកស្រីវេជ្ជបណ្ឌិត	**មាន**	**សារឿន**
៦-លោកស្រីវេជ្ជបណ្ឌិត	**អូន**	**សុខា**
៧-លោកវេជ្ជបណ្ឌិត	**នាង**	**ម៉ុនសុផល្លី**
៨-លោកវេជ្ជបណ្ឌិត	**កែវ**	**ណារិទ្ធ**
៩-លោកវេជ្ជបណ្ឌិត	**ឆាយ**	**នាង**
១០-លោកវេជ្ជបណ្ឌិត	**ខាន់**	**ចិន្តសុផារ៉ា**

១១-លោកវេជ្ជបណ្ឌិត អ៊ិន ឈយន
១២-លោកវេជ្ជបណ្ឌិត អ៊ុច ឧត្តី
១៣-លោកគ្រូពេទ្យបឋម យ៉ាំង សារ៉េត
១៤-លោកគ្រូពេទ្យបឋម ម៉ាឃ ជាវុធ
១៥-លោកស្រីពេទ្យបឋម ថី ម៉ូរី
១៦-ពេទ្យបឋម ភាំង សុវណ្ណារិទ្ធ
១៧-ពេទ្យមធ្យម ឃី ស្រេង
១៨-ពេទ្យមធ្យម ឈឹម សុផុន
១៩-ពេទ្យបឋម ភ្នំ សេដ្ឋា
២០-លោកស្រី ម៉ាស សុដ្ឋាវី

ខ_មេដាយប្រាក់ការងារ :

១-លោកវេជ្ជបណ្ឌិត ស្រី វណ្ណថា
២-លោកវេជ្ជបណ្ឌិត ថែម គុណសារោ
៣-លោកស្រី កើត ស៊ីយុត្តិ
៤-លោកវេជ្ជបណ្ឌិត ហៅ ស៊ីថា
៥-លោកវេជ្ជបណ្ឌិត ថៃ សិលា
៦-លោកវេជ្ជបណ្ឌិត ស៊ី រ៉ា
៧-លោកវេជ្ជបណ្ឌិត ហ៊ិន សុវុឌ្ឍ
៨-លោកវេជ្ជបណ្ឌិត យោគ ឌីលីន
៩-លោកវេជ្ជបណ្ឌិត ម៉ែន ឌល្លុន
១០-លោកវេជ្ជបណ្ឌិត ស្វ ជុំ
១១-លោកវេជ្ជបណ្ឌិត ប៊ូ សាវុធ
១២-លោកវេជ្ជបណ្ឌិត កែវ ណារិទ្ធ
១៣-លោកវេជ្ជបណ្ឌិត អ៊ិន សុវុឌ្ឍារ៉ា
១៤-លោកវេជ្ជបណ្ឌិត ស្រី សុម៉ាលីន
១៥-លោកវេជ្ជបណ្ឌិត សុខ ប៊ុនចាន់
១៦-លោកវេជ្ជបណ្ឌិត ឡុង វុឌ្ឍី
១៧-លោកវេជ្ជបណ្ឌិត ម៉ៅ សារី
១៨-លោកវេជ្ជបណ្ឌិត កែវ សុវណ្ណ
១៩-លោកវេជ្ជបណ្ឌិត គៀន អាន់ថារ៉ូ
២០-លោកស្រី ឃុន សោភ័ណ
២១-លោកគ្រូពេទ្យមធ្យម សេង ឌីឡែន
២២-លោកស្រីពេទ្យបឋម គីម សុភាព

២៣-ពេទ្យបឋម សៀង ចន្ថា
២៤-ពេទ្យបឋម ឌួន រតនា
២៥-លោកឧសេថឧត្តម ឡាយ សេងហុក
២៦-ពេទ្យមធ្យម ស៊ឹង តារា
២៧-ពេទ្យបឋម ហ៊ិន វាសនា
២៨-លោក ទឹង ម៉ឹង

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៤

ហ៊ុន សែន

<u>កន្លែងទទួល</u> :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

※※※※※※

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនដល់មន្ត្រីនគរបាលជាតិចំនួន **៤៧រូប** ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :

ក / **មេដាយមាសការងារ ចំនួន ១០ រូប**

១- លោកវរសេនីយ៍ទោ	**នាង**	**និរត្ន**	នាយការិយាល័យ នៃនាយកដ្ឋានវិទ្យុទាក់ទង
២- លោកវរសេនីយ៍ត្រី	**សែត**	**ចន្ថាសិទ្ធិ**	នាយរងការិយាល័យ នៃនាយកដ្ឋានបុគ្គលិក
៣- លោកវរសេនីយ៍ត្រី	**កៅ**	**មុយយាង**	នាយរងការិយាល័យ នៃនាយកដ្ឋានបុគ្គលិក
៤- លោកអនុសេនីយ៍ឯក	**ខាំដែង**	**សារតី**	នាយផ្នែក នៃនាយកដ្ឋានបុគ្គលិក
៥- លោកអនុសេនីយ៍ឯក	**អ៊ុង**	**សារុំ**	នាយផ្នែក នៃនាយកដ្ឋានបុគ្គលិក
៦- លោកអនុសេនីយ៍ឯក	**ឡុច**	**ម៉ុងដែន**	នាយផ្នែក នៃនាយកដ្ឋានបុគ្គលិក
៧- លោកអនុសេនីយ៍ត្រី	**អៀង**	**ប៊ុនលីម**	នាយប៉ុស្តិ៍ការពារគោលដៅ នៃនាយកដ្ឋាននគរបាលការពារ
៨- លោកព្រិន្ទបាលឯក	**មុត**	**អាន**	នាយរងប៉ុស្តិ៍ការពារគោលដៅ នៃនាយកដ្ឋាននគរបាលការពារ
៩- លោកព្រិន្ទបាលទោ	**ទ៉ុច**	**សុខា**	ប្រធានក្រុមការពារគោលដៅ នៃនាយកដ្ឋាននគរបាលការពារ
១០- លោកពលបាលឯក	**ឈឹម**	**សុធី**	អនុប្រធានក្រុមការពារគោលដៅនៃនាយកដ្ឋាននគរបាលការពារ

ខ / **មេដាយប្រាក់ការងារ ចំនួន ៣៥ រូប**

១- លោកវរសេនីយ៍ទោ	**ឃឹម**	**សុវណ្ណ**	នាយការិយាល័យ នៃនាយកដ្ឋានវិទ្យុទាក់ទង
២- លោកវរសេនីយ៍ទោ	**ញឹម**	**សារិទ្ធ**	នាយការិយាល័យ នៃនាយកដ្ឋានវិទ្យុទាក់ទង
៣- លោកវរសេនីយ៍ទោ	**ថាប់**	**សំផល**	នាយការិយាល័យ នៃនាយកដ្ឋានវិទ្យុទាក់ទង
៤- លោកវរសេនីយ៍ត្រី	**អ៊ុង**	**សុខណា**	នាយរងការិយាល័យ នៃនាយកដ្ឋានវិទ្យុទាក់ទង
៥- លោកវរសេនីយ៍ត្រី	**មៀង**	**គុង**	នាយរងការិយាល័យ នៃនាយកដ្ឋានវិទ្យុទាក់ទង
៦- លោកវរសេនីយ៍ត្រី	**សូ**	**សំណាង**	នាយរងការិយាល័យ នៃនាយកដ្ឋានវិទ្យុទាក់ទង

៧- លោកវរសេនីយ៍ត្រី អ៊ុក សម្បត្តិ នាយរងការិយាល័យ២ នៃនាយកដ្ឋានវិទ្យុទាក់ទង
៨- លោកស្រីអនុសេនីយ៍ឯក ចាន់ ធីនា នាយផ្នែក នៃនាយកដ្ឋានបុគ្គលិក
៩- លោកអនុសេនីយ៍ឯក អ៊ុង យិនឡាយ នាយផ្នែក នៃនាយកដ្ឋានបុគ្គលិក
១០- លោកអនុសេនីយ៍ឯក កៅ សុចន្ទា នាយផ្នែក នៃនាយកដ្ឋានវិទ្យុទាក់ទង
១១- លោកអនុសេនីយ៍ឯក យ៉ាង រិទ្ធី នាយផ្នែក នៃនាយកដ្ឋានវិទ្យុទាក់ទង
១២- លោកអនុសេនីយ៍ទោ នូ សុខឃាង នាយរងផ្នែក នៃនាយកដ្ឋានបុគ្គលិក
១៣- លោកអនុសេនីយ៍ទោ ម៉ៅ ប៊ុនរិទ្ធ នាយរងផ្នែក នៃនាយកដ្ឋានបុគ្គលិក
១៤- លោកអនុសេនីយ៍ទោ ស៊ុម យុទ្ធី នាយរងផ្នែក នៃនាយកដ្ឋានវិទ្យុទាក់ទង
១៥- លោកអនុសេនីយ៍ត្រី ខៀវ យ៉ុន នាយរងផ្នែក នៃនាយកដ្ឋានបុគ្គលិក
១៦- លោកព្រិន្ទបាលឯក នឹម សុន មន្ត្រីការពារគោលដៅ នៃនាយកដ្ឋាននគរបាលការពារ
១៧- លោកព្រិន្ទបាលទោ ឃួន សារឹម ប្រធានក្រុមការពារគោលដៅ នៃនាយកដ្ឋាននគរបាលការពារ
១៨- លោកព្រិន្ទបាលទោ ឈុន ធីរៈ មន្ត្រីការពារគោលដៅ នៃនាយកដ្ឋាននគរបាលការពារ
១៩- លោកព្រិន្ទបាលទោ សៀន ខេមរ៉ា មន្ត្រីការពារគោលដៅ នៃនាយកដ្ឋាននគរបាលការពារ
២០- លោកព្រិន្ទបាលទោ ឡុង តារ៉ា មន្ត្រីការពារគោលដៅ នៃនាយកដ្ឋាននគរបាលការពារ
២១- លោកពលបាលឯក ឃុត ឡឿន អនុប្រធានក្រុមការពារគោលដៅនៃនាយកដ្ឋាននគរបាលការពារ
២២- លោកពលបាលឯក ម៉ាង ចំរើន អនុប្រធានក្រុមការពារគោលដៅនៃនាយកដ្ឋាននគរបាលការពារ
២៣- លោកពលបាលឯក ជួន ឆោមអេង អនុប្រធានក្រុមការពារគោលដៅនៃនាយកដ្ឋាននគរបាលការពារ
២៤- លោកពលបាលទោ យ៉ែម អូន មន្ត្រីការពារគោលដៅ នៃនាយកដ្ឋាននគរបាលការពារ
២៥- លោកពលបាលទោ ឯក សារឿន មន្ត្រីការពារគោលដៅ នៃនាយកដ្ឋាននគរបាលការពារ
២៦- លោកពលបាលទោ នឹង ឃឹង មន្ត្រីការពារគោលដៅ នៃនាយកដ្ឋាននគរបាលការពារ
២៧- លោកពលបាលទោ ណុប ចន្ទ្ធថន មន្ត្រីការពារគោលដៅ នៃនាយកដ្ឋាននគរបាលការពារ
២៨- លោកពលបាលទោ ជា ទីបុល មន្ត្រីការពារគោលដៅ នៃនាយកដ្ឋាននគរបាលការពារ
២៩- លោកពលបាលទោ នួន ថុង មន្ត្រីការពារគោលដៅ នៃនាយកដ្ឋាននគរបាលការពារ
៣០- លោកពលបាលត្រី ហ៊ាន សុជាតិ មន្ត្រីការពារគោលដៅ នៃនាយកដ្ឋាននគរបាលការពារ
៣១- លោកពលបាលត្រី ពេញ ឈឿន មន្ត្រីការពារគោលដៅ នៃនាយកដ្ឋាននគរបាលការពារ
៣២- លោកពលបាលត្រី ឡឹក សោភា មន្ត្រីការពារគោលដៅ នៃនាយកដ្ឋាននគរបាលការពារ
៣៣- លោកពលបាលត្រី សុខ ធុល មន្ត្រីការពារគោលដៅ នៃនាយកដ្ឋាននគរបាលការពារ
៣៤- លោកពលបាលត្រី ចិន ឡាត់ មន្ត្រីការពារគោលដៅ នៃនាយកដ្ឋាននគរបាលការពារ
៣៥- លោកពលបាលត្រី យន គន្ធា មន្ត្រីការពារគោលដៅ នៃនាយកដ្ឋាននគរបាលការពារ

គ / <u>មេជាងសិប្បការងារ ចំនួន ០២ រូប</u>

១- លោកពលបាលទោ ចឹម រី មន្ត្រី ការពារគោលដៅ នៃនាយកដ្ឋាននគរបាលការពារ
២- លោកពលបាលត្រី សាន គាត មន្ត្រី ការពារគោលដៅ នៃនាយកដ្ឋាននគរបាលការពារ

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបាន លទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និងមាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១០ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការអនុវត្តវិន័យនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស/ ៩៤ / ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/ រកម /០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា១ : ត្រូវបានអនុវត្តវិន័យចំពោះវរៈសេនីយ៍ឯក **គាន់ ម៉ុនសេខ** អត្តលេខ ០១៩៨ ឋានៈអនុប្រធាននាយកដ្ឋាននគរបាលស្ថិតិ និងលិខិតឆ្លងដែន នៃក្រសួងមហាផ្ទៃ ដោយរូបភាពដកហូតមុខតំណែងឋានន្តរសក្តិ និងបណ្តេញចេញពីក្របខ័ណ្ឌនគរបាលជាតិ ។
មូលហេតុ : បានបោះបង់ចោលការងារ ។

មាត្រា២ : ប្រាក់បៀវត្សរ៍ របបឧបត្ថម្ភផ្សេងៗ និងក្របខណ្ឌ ត្រូវបានលុបឈ្មោះចេញពីក្របខ័ណ្ឌនគរបាលជាតិ ចាប់ពីខែ.[illegible] ឆ្នាំ ២០០.៤ នេះតទៅ ។

មាត្រា៣ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយ នឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ. ថ្ងៃទី ០៨ ខែមករា ឆ្នាំ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *ឯកសារ កាលប្បវត្ត*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៤-០៣-១៣២ ប្រក

ប្រកាស
ស្តីពី
ការបង្កើតគណៈកម្មការវិនិយោគទុនបំរុងអន្តរជាតិ

ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០២/០៣៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការតែងតាំងឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ជាថ្មីម្តងទៀត
- យោងតាមប្រកាសលេខ ធ៨៩៨-៣៨៥ប្រក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៨ ស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់អង្គភាពក្រោមឱវាទ
- យោងតាមប្រកាសលេខ ធ៨០៣-១២៣ប្រក ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ ២០០៣ ស្តីពីរចនាសម្ព័ន្ធនាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ និងមុខងារ-ភារកិច្ចរបស់ការិយាល័យក្រោមឱវាទ
- យោងតាមសំណូមពរការងារចាំបាច់របស់ធនាគារជាតិនៃកម្ពុជា

សំរេច

ប្រការ ១.- បង្កើតគណៈកម្មការមួយមានឈ្មោះថា "គណៈកម្មការវិនិយោគទុនបំរុងអន្តរជាតិរបស់ធនាគារជាតិនៃកម្ពុជា" ដែលក្នុងប្រកាសជាបន្តបន្ទាប់ហៅថា "**គណៈកម្មការ**" ។

ប្រការ ២.- គណៈកម្មការរួមមានសមាសភាព៤រូបដូចខាងក្រោម :

- ទេសាភិបាល ប្រធាន
- អគ្គនាយក សមាជិក
- ប្រធាននាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ សមាជិក
- ប្រធាននាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច សមាជិក

គណៈកម្មការអាចរួមប្រជុំជាផ្លូវការមានប្រសិទ្ធភាពបាន លុះត្រាតែបំពេញបានលក្ខខណ្ឌទាំង២ :

- ទេសាភិបាល
- សមាជិក២រូបយ៉ាងតិចមានវត្តមាន ។

គណៈកម្មការអាចអញ្ជើញមន្ត្រីជំនាញផ្សេងទៀតឱ្យចូលរួមក្នុងការប្រជុំតាមការចាំបាច់ ។

ប្រការ ៣.- ការប្រជុំរបស់គណៈកម្មការត្រូវធ្វើយ៉ាងហោចណាស់មួយដងក្នុងមួយខែ ។ ក្នុងករណីមានតំរូវការចាំបាច់អំពីលក្ខខណ្ឌសេដ្ឋកិច្ច រូបិយវត្ថុ និងហិរញ្ញវត្ថុ ប្រធានគណៈកម្មការអាចកោះប្រជុំគណៈ-កម្មការនៅពេលណាក៏បាន ។

ប្រការ ៤.- គណៈកម្មការទទួលបន្ទុក កសាងយុទ្ធសាស្ត្រនៃការវិនិយោគទុនបំរុងអន្តរជាតិនៅលើទីផ្សារ និងរៀបចំបង្កើតឧបករណ៍ព្រមទាំងបែបបទទាំងឡាយសំរាប់គ្រប់គ្រងហានិភ័យដោយប្រុងប្រយ័ត្ន ។

ប្រការ ៥.- នៅក្នុងអង្គប្រជុំនីមួយៗ គណៈកម្មការកំណត់ទិសដៅនៃនយោបាយគ្រប់គ្រងទុនបំរុងអន្តរជាតិសំរាប់ការអនុវត្តន៍ របស់នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ រហូតដល់ការប្រជុំបន្ទាប់ទៀត ជាអាទិ៍រួមមាន សេចក្តីសំរេចដូចខាងក្រោម :

ក- កំណត់សមាសភាពនៃរូបិយប័ណ្ណនីមួយៗ នៅក្នុងសំពៀតវិនិយោគ

គណៈកម្មការរំលែកសមាមាត្រនៃរូបិយប័ណ្ណទាំងឡាយឱ្យបានសមស្របនៅក្នុងបរិមាណសរុបនៃទុនបំរុងអន្តរជាតិ ។ សំរាប់ការងារនេះ គណៈកម្មការត្រូវយកចិត្តទុកដាក់អំពីពតិមានសេដ្ឋកិច្ចដែលមានក្នុងដៃ និងជាអាទិ៍រចនាសម្ព័ន្ធនៃទុនបំរុង អត្រាការប្រាក់ដែលកំពុងត្រូវបានអនុវត្តចំពោះរូបិយប័ណ្ណនីមួយៗ ការវិវត្តន៍ដែលអាចទស្សទាយបាន អំពីយុគភាពនៃរូបិយប័ណ្ណ

និងភាពចាំបាច់នៃការបំបែកការវិនិយោគទៅលើរូបិយប័ណ្ណច្រើនមុខ សំដៅបន្ថយហានិភ័យប្តូរប្រាក់ ។

ខ- កំណត់រយៈពេលវិនិយោគ

គណៈកម្មការកំណត់រយៈពេលសមស្របសំរាប់ការវិនិយោគ ។ សំរាប់ការងារនេះ គណៈកម្មការត្រូវយកចិត្តទុកដាក់អំពីពត៌មានសេដ្ឋកិច្ចដែលមានក្នុងដៃ និងជាអាទិ៍ឥណប្រតិទានជាក់ស្តែងនៃការវិនិយោគ ខ្សែកោងអត្រាការប្រាក់នៃរូបិយប័ណ្ណចំបងៗ និងភាពចាំបាច់នៃការតាមដានសាច់ប្រាក់ងាយស្រួលរបស់ការវិនិយោគ សំដៅរក្សាលទ្ធភាពលក់រូបិយប័ណ្ណទៅវិញបានភ្លាមៗ និងធ្លាក់ការខាតបង់ ប្រសិនបើមានតំរូវការចាំបាច់ ។

គ- កំណត់ឧបករណ៍

គណៈកម្មការកំណត់ឧបករណ៍វិនិយោគសមស្រប ដែលត្រូវប្រើប្រាស់ជាអាទិ៍ ប័ណ្ណរតនាគារ ប្រាក់បញ្ញើក្នុងធនាគារ និងប្រតិបត្តិការឱ្យខ្ចីប្រចាំថ្ងៃ (overnight) និងមានកាលកំណត់ ។ សំរាប់ការងារនេះ គណៈកម្មការយកចិត្តទុកដាក់អំពីអត្រាការប្រាក់នៃឧបករណ៍ទាំងនោះ និងភាពចាំបាច់នៃការរក្សាឱ្យមានការបំបែកសំពៀតវិនិយោគ ។

ត្រូវបានហាមឃាត់មិនឱ្យវិនិយោគទុនបំរុងអន្តរជាតិទៅលើទីផ្សារនៃផលិតផលដេរិវេទិស្សន៍ និងផលិតផលដែលមានរចនាសម្ព័ន្ធស្មុគស្មាញ ។

ប្រការ ៦.- គណៈកម្មការតាក់តែងវិធានទាំងឡាយសំរាប់ការវិនិយោគ សំដៅគ្រប់គ្រងទុនបំរុងអន្តរជាតិនៅក្នុងលក្ខខណ្ឌសុវត្ថិភាពប្រសើរបំផុត ដែលជាអាទិ៍រួមមានវិធានដូចខាងក្រោម :

ក- អនុញ្ញាតការផ្ទេរសិទ្ធិសំរាប់ធ្វើអន្តរាគមន៍លើទីផ្សារ

អន្តរាគមន៍លើទីផ្សារទាមទារការសំរេចចិត្តភ្លាមៗ ដែលមិនត្រូវបានរំខានដោយខ្សែចង្វាក់បានានុក្រមឡើយ ។ សំរាប់ការងារនេះ មន្ត្រីទទួលបន្ទុកត្រូវតែបានទទួលការផ្ទេរសិទ្ធិឱ្យធ្វើប្រតិបត្តិការអន្តរាគមន៍លើទីផ្សារ ។

វិធានទាំងឡាយក្នុងការផ្ទេរសិទ្ធិឱ្យមន្ត្រីទទួលបន្ទុកធ្វើការវិនិយោគ ត្រូវតែរួមមានកំរិតកំណត់ទាំងឡាយអំពី :

- ចំនួនប្រាក់
- គណប្រតិទាន
- គុណភាពនៃសមភាគី ដោយផ្អែកលើចំណាត់ថ្នាក់
- រូបិយប័ណ្ណ

ប្រធាននាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ ត្រូវធានាឱ្យបានអំពីចំនួនប្រាក់ដែលត្រូវបានផ្ទេរសិទ្ធិឱ្យមន្ត្រីទទួលបន្ទុកនីមួយៗ មានកំរិតសមស្របជាមួយវិធានជាយុទ្ធសាស្ត្រដែលបានចែងក្នុងប្រការ៥ ខាងលើ ។

ការអនុវត្តន៍ទាំងឡាយណាលើសពីកំរិតកំណត់ដែលបានផ្ទេរសិទ្ធិ ត្រូវតែបានរាយការណ៍ជាបន្ទាន់ដល់គ្រប់សមាជិកគណៈកម្មការ ។ អគ្គនាយកអាចនឹងអនុញ្ញាតឱ្យទទួលស្គាល់ភាពត្រឹមត្រូវនៃការអនុវត្តន៍លើសកំរិតគណទាននោះ ឬតំរូវឱ្យរៀបចំប្រតិបត្តិការជាថ្មីដើម្បីវិលមកគោរពកំរិតកំណត់ឡើងវិញ ។ រាល់ព្រឹត្តិការណ៍នៃការអនុវត្តន៍លើសកំរិតនៃការសំរេចចិត្តដែលពាក់ព័ន្ធត្រូវតែជាកម្មវត្ថុនៃការពិភាក្សាក្នុងអង្គប្រជុំបន្ទាប់របស់គណៈកម្មការ ។

ខ- កំណត់វិធានអំពីការងាររាយការណ៍ :

ដើម្បីជាការត្រួតពិនិត្យលើការអនុវត្តន៍សេចក្តីសំរេចរបស់ខ្លួន គណៈកម្មការត្រូវកំណត់ឱ្យច្បាស់អំពីពត៌មានទាំងឡាយដែលនឹងត្រូវផ្តល់ជូនតាមរយៈពេលទៀងទាត់ទៅដល់គ្រប់សមាជិក។ របាយការណ៍នោះត្រូវរួមមាន :

- ពត៌មានលំអិតអំពីការវិនិយោគតាមប្រភេទរូបិយប័ណ្ណ តាមសមភាគី និងតាមគណប្រតិទាន
- ការវាយតម្លៃអំពីសំពៀតវិនិយោគតាមថ្លៃទីផ្សារ ប្រសិនបើឧបករណ៍ដែលបានវិនិយោគអាចមានថ្លៃជាទៀងទាត់
- លទ្ធផលដែលទទួលបាន និងលទ្ធផលដែលនឹងត្រូវទទួលបានរបស់សំពៀតវិនិយោគដោយបញ្ជាក់ជាអាទិ៍នូវកំរៃការប្រាក់ដែលអាចទទួលបាន និងថ្លៃទីផ្សារ ។

គណៈកម្មការអាចទាមទារបន្ថែមនូវពត៌មានចាំបាច់ទាំងឡាយថែមទៀត ។

ប្រការ ៧.- ក្នុងការប្រជុំគណៈកម្មការត្រូវតែទទួលបានយ៉ាងហោចណាស់នូវព័ត៌មានទាំងឡាយដូចខាងក្រោម:

ក- ការវិវត្តន៍នៃការវិនិយោគ និងលទ្ធផលពេលនាពីត្រឹមពេលប្រជុំលើកមុន

ប្រធាននាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់រំលឹកជូនអង្គប្រជុំពីសេចក្តីសំរេចទាំងឡាយដែលបានប្រកាន់យកកាលពីសម័យប្រជុំលើកមុន និងរាយការណ៍អំពីសកម្មភាពនាយកដ្ឋាន ដែលរួមមាន :

- ព័ត៌មានលំអិតនៃការវិនិយោគ គិតត្រឹមសម័យប្រជុំលើកមុន
- ប្រតិបត្តិការដែលបានអនុវត្ត គិតចាប់ពីសម័យប្រជុំលើកមុន
- ព័ត៌មានលំអិតនៃការវិនិយោគ គិតមកដល់សម័យប្រជុំនេះ
- ការត្រួតពិនិត្យអំពីការគោរពក្រិតកំណត់
- លទ្ធផលទទួលបាន និងលទ្ធផលរង់ចាំទទួល គិតចាប់ពីសម័យប្រជុំលើកមុន

ប្រធាននាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ត្រូវរាយការណ៍ជូនអង្គប្រជុំផងដែរនូវព័ត៌មានទាំងឡាយដែលបានទទួលស្តីអំពីទីផ្សារ ។

ខ- ការវិវត្តន៍នៃស្ថានភាពសេដ្ឋកិច្ច រូបិយវត្ថុ និងហិរញ្ញវត្ថុជាតិ និងអន្តរជាតិ :

ប្រធាននាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច ត្រូវធ្វើរបាយការណ៍អំពីស្ថានភាពសេដ្ឋកិច្ចរូបិយវត្ថុ និងហិរញ្ញវត្ថុ ដែលរួមមានជាអាទិ៍ ការវិវត្តន៍កើតមានឡើងចាប់ពីសម័យប្រជុំលើកមុនស្តីអំពី :

- អត្រាការប្រាក់របស់ទីផ្សារហិរញ្ញវត្ថុចំបងៗនៃសកលលោក (អឺរ៉ូ, យ៉េន, ដុល្លារអាមេរិក) និងតំបន់ (បាតថៃ, ដុល្លារសឹង្ហបុរី, ដុល្លារហុងកុង, ...)
- អត្រាប្តូរប្រាក់នៃរូបិយប័ណ្ណទាំងនេះ ធៀបជាមួយប្រាក់រៀល
- ទីផ្សារហិរញ្ញវត្ថុចំបងៗ

ប្រធាននាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចត្រូវរាយការណ៍ជូនអង្គប្រជុំផងដែរនូវការព្យាករណ៍ការវិវត្តន៍របស់សន្ទស្សន៍ទាំងឡាយខាងលើ និងព័ត៌មានទាំងឡាយដែលពាក់ព័ន្ធដល់នយោបាយវិនិយោគទុនបំរុងអន្តរជាតិរបស់គណៈកម្មការ ។

ប្រការ ៨.- ប្រធាននាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ មានតួនាទីជាអ្នកគ្រប់គ្រងលេខាធិការដ្ឋានរបស់គណៈកម្មការ ដោយគាត់តែងកំណត់ហេតុរបស់អង្គប្រជុំគណៈកម្មការ ហើយផ្តល់ជូននៅថ្ងៃបន្ទាប់នៃការប្រជុំទៅអ្នកចូលរួមទាំងអស់ដើម្បីធ្វើការផ្តល់មតិ ហើយតំរូវឱ្យបញ្ជូនត្រឡប់វិញមួយថ្ងៃក្រោយមកទៀត ។ បើពុំមានប្រតិកម្មតាមកាលកំណត់ខាងលើទេ កំណត់ហេតុត្រូវបានចាត់ទុកថាទទួលបានការឯកភាព ។

ដូច្នេះ យ៉ាងយូរបំផុត២ថ្ងៃក្រោយសម័យប្រជុំគណៈកម្មការ កំណត់ហេតុស្ថាពរត្រូវបានសំរេច និងផ្ញើជូនទៅគ្រប់អ្នកចូលរួមប្រជុំ ។ ប្រធាននាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់មានភារកិច្ចរក្សាទុកកំណត់ហេតុទាំងអស់ និងចងក្រងឱ្យបានពេញលេញតាមលំដាប់លំដោយលេខរៀង ។

ប្រការ ៩.- រាល់ប្រកាស ឬលិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ១០.- អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា ព្រមទាំងសាមីជននៅក្នុងប្រការ២ ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ១១.- ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៣

ទេសាភិបាល

ជា ចាន់តូ

<u>កន្លែងទទួល</u>

- ដូចប្រការ ១០

"ដើម្បីអនុវត្ត"

- កាលប្បវត្តិ
- ឯកសារ

<u>ចំលងជូន</u>

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីជ្រាបជាពត៌មាន"

- នាយកដ្ឋានរដ្ឋបាលទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
No. ០០៧ MOC / M 2004

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០៤

ប្រកាស
ស្តីពីការតែងតាំងអាណាប័កផ្ទេរសិទ្ធ

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បាឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/ ០១៩៦ / ១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ ក្រសួង ពាណិជ្ជកម្ម
- បានឃើញការចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : ឯកឧត្តម **កែវ សុខណៃ** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ត្រូវទទួលជាអាណាប័កផ្ទេរសិទ្ធក្នុងការគ្រប់គ្រងឥណទានថវិកា ឆ្នាំ ២០០៤ របស់ក្រសួង ពាណិជ្ជកម្ម " រដ្ឋបាលកណ្តាល " ។

ប្រការ ២ : អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការដ្ឋាន នាយកខុទ្ទកាល័យ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម ប្រសិទ្ធ

ចំលងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ដូចប្រការ១ និង ប្រការ២ " ដើម្បីអនុវត្ត "
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 (Kingdom of Cambodia)
Minister's Mobile Phone (855-12) 821888 Facsimile: (855-23) 213288
URL : http://www.moc.gov.kh E-Mail : champrasidh@hotmail.com
Staff's Mobile Phones: (855-12) 818883 / 881223 Facsimile: (855-23) 426396

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ : ៥៩៨ ប្រក.កសក

ប្រកាស

ស្តីពី

បញ្ជីឈ្មោះថ្នាំកសិកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៩៨ ស្តីពីបមាណី និង ការគ្រប់គ្រងសម្ភារៈកសិកម្ម
- បានឃើញសារាចរណែនាំលេខ ៣៤៥ សរណន.កសក ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការអនុវត្តអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៨
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ស ម្រេ ច

ប្រការ ១ : កំណត់បញ្ជីឈ្មោះថ្នាំកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានបី (៣) ប្រភេទ ដូចខាងក្រោម :

១.១. បញ្ជីឈ្មោះថ្នាំកសិកម្មដែលមិនអនុញ្ញាតឱ្យប្រើប្រាស់ ដូចមានក្នុងឧបសម្ព័ន្ធទី ១ នៃប្រកាសនេះ។

១.២.. បញ្ជីឈ្មោះថ្នាំកសិកម្មអនុញ្ញាតឱ្យប្រើប្រាស់ជាបណ្តោះអាសន្នដោយមានលក្ខខណ្ឌ ដូចមានក្នុងឧបសម្ព័ន្ធទី ២ នៃប្រកាសនេះ ។

១.៣. បញ្ជីឈ្មោះថ្នាំកសិកម្មដែលអនុញ្ញាតឱ្យប្រើប្រាស់ ដូចមានក្នុងឧបសម្ព័ន្ធទី ៣នៃប្រកាសនេះ។

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Nº 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D Phnom Penh, Cambodia Phone : (023) 211 351/211 352, Fax : (855) 23 - 217 320

ប្រការ ២ : បញ្ជីឈ្មោះថ្នាំកសិកម្មទាំងបី (៣) ប្រភេទក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ អាចកែប្រែក្នុងករណីមានការចាំបាច់ ។

ប្រការ ៣ : អគ្គនាយកក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានកៀវគ្រសាស្ត្រ និង កែលំអដីកសិកម្ម និង ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ៦ ឆ្នាំ ២០០៣

រដ្ឋមន្ត្រី

ចាន់ សារុន

កន្លែងទទួល

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងផែនការ
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- គ្រប់សាលាខេត្ត ក្រុង
- គ្រប់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទខេត្ត ក្រុង
- ដូចប្រការ ៣
- ឯកសារ- កាលប្បវត្តិ

ឧបសម្ព័ន្ធទី១នៃប្រកាសលេខៈ ៥៩៨ ប្រក.កសក ចុះថ្ងៃទី១៥ ខែ ធ្នូ ឆ្នាំ២០០៣
ស្តីពី បញ្ជីឈ្មោះថ្នាំកសិកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា

បញ្ជីឈ្មោះថ្នាំកសិកម្មដែលមិនអនុញ្ញាតឱ្យប្រើប្រាស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា

LIST OF PESTICIDES BANNED FOR USE IN THE KINGDOM OF CAMBODIA

១

លរ No.	ឈ្មោះទូទៅ COMMON NAMES	អំពើ USE	ចំណាត់ថ្នាក់ពុលតាមអង្គការសុខភាពពិភពលោក Toxicity Classification byWHO	ក្រុមគីមី FAMILY
01	1,1,2,2-Tetrachloroethane	FM		Org
02	2,4,5-T	H	O	OC
03	2,4,5-TP (Fenoprop)	H	O	OC
04	Aldicarb	I	Ia	CA
05	Aldoxycarb (Aldicarb sulfone)	I	O	
06	Aldrin	I	O	OC
07	Aminocarb	I	O	Org
08	Amitraz	I	O	Triazapentadiene
09	Antu	R	O	CA
10	Aramite	I	O	OC
11	Arsenic compound (AS)	F		AS
12	BHC / HCH , Lindane	I	II	OC
13	Binapacryl	I , F	O	Org
14	Bis (Tributyltin) oxide		O	
15	Bromophos	I	O	
16	Bromophos ethyl	I	O	
17	Cadmium Compound (Cd)	F		Inorg
18	Calcium arsenate	I	Ib	AS
19	Calcium cyanide	FM	Ib	Inorg
20	Camphechlor (Toxaphene , Polychlorcamphene)	I	O	OC
21	Captafol	F	Ia	OC
22	Captan	F	Un	PD
23	Carbophenothion	I	O	
24	Chlordane	I	II	OC
25	Chlordecone	I	O	OC
26	Chlordimeform	I	O	Formamidine
27	Chlorfenvinphos / CVP	I	Ib	OP
28	Chlormephos	I	Ia	OP
29	Chlorthiophos	I	O	OP
30	Coumaphos	AC	Ia	OP
31	Crimidine	R	O	
32	Crotoxyphos	I	O	
